## ផាន់ ឈុនរ៉េត



**អាសយដ្ឋាន:** ផ្ទះលេខ៦ ផ្លូវលេខ៨៦ ភូមិ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ
**អាយុ:** ៥៤ ឆ្នាំ
**ស្ថានភាពគ្រួសារ:**រៀបការមានកូន៥នាក់ និងចៅ ៣ នាក់ (កូន៤នាក់ធ្វើការ និងម្នាក់កំពុងរៀននៅមហាវិទ្យាល័យ)
**ឈ្មោះហៅក្រៅ:** យាយឡែត
**មុខរបរ:** មេផ្ទះ
**ប័ណ្ណកម្មសិទ្ធិ:** ត្រូវគេកាត់ចេញដោយបំពាន
**ការចោទប្រកាន់:** ក. បទកាន់កាប់ដោយខុសច្បាប់លើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ
ខ. បទប្រឆាំងអាជ្ញាធរសាធារណៈ
**ថ្ងៃចាប់ខ្លួន:** ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២
**ថ្ងៃសវនាការ:** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
**វិនិច្ឆ័យទោស:**ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ២ឆ្នាំកន្លះ ដោយមានស្ថានទម្ងន់ទោស (អត់មានព្យួរទោសទេ)

*កូនប្រុសផាន់ ឈុនរ៉េត ឈ្មោះ អ៊ួង សុធា និយាយថា "នៅផ្ទះមានសភាពស្ងាត់ជ្រងំចាប់ តាំងពីបាត់ម្តាយខ្ញុំមក....ឥឡូវនេះខ្ញុំបានចូលរួមតវ៉ា នេះក៏ដើម្បីម្តាយខ្ញុំ"*

ផាន់ ឈុនរ៉េត និងក្រុមគ្រួសារបានរស់នៅក្នុងតំបន់បឹងកក់តាំងពីឆ្នាំ១៩៩៧ មកម្ល៉េះ។ ពេលនេះគាត់មានអាយុ៥៤ឆ្នាំ មានកូន៥នាក់ និងចៅ៣នាក់។ មកទល់នឹងថ្ងៃចាប់ខ្លួន ផាន់ ឈុនរ៉េត គឺជាបុគ្គលសំខាន់ក្នុងគ្រួសារដែលចេញមុខតវ៉ាដើម្បីដីធ្លី ប៉ុន្តែបច្ចុប្បន្ននេះ កូនប្រុសរបស់គាត់បានបន្តចូលរួមសកម្មភាពតវ៉ាតាំងនាមឲ្យផាន់ ឈុនរ៉េត។

អ្វីដែលជាសេចក្តីព្រួយបារម្ភដ៏ធំបំផុតរបស់ អ៊ួង សុធា នោះគឺសុខភាពរបស់ម្តាយ។ ផាន់ ឈុនរ៉េត មានបញ្ហាសុខភាពដែលតម្រូវឲ្យមានទទួលការព្យាបាលជាប្រចាំ។

អ៊ួង សុធា បានទទួលដំណឹងពីអ្នកជិតខាងថា ម្តាយរបស់អ៊ួង សុធាត្រូវបានគេចាប់ខ្លួននៅថ្ងៃទី២២ ខែឧសភា។ ពេលដែល អ៊ួង សុធា និងប្អូនៗបានទៅជួបម្តាយជាលើកដំបូងនៅពន្ធនាគារ។ អ្នកទាំងអស់បានឃើញអ្នកម្តាយរបស់មានការព្រួយបារម្ភអំពីសុខភាពជាខ្លាំងរបស់គាត់។ អ៊ួង សុធា និងប្អូនៗបានជួបនិយាយជាមួយម្តាយបានត្រឹមតែ ៥នាទីទេ។

មិនដូចសកម្មជនបឹងកក់ខ្លះ ផាន់ ឈុនរ៉េត មិនដែលត្រូវគេចាប់ខ្លួនពីមុខមកទេ។ ដូច្នេះ ធ្វើអោយក្រុមគ្រួសារផាន់ ឈុនរ៉េត មានការលំបាកក្នុងការយល់ ថាហេតុអីបានជាគេសំដៅចាប់គាត់។ ជាពិសេសចៅរបស់ ផាន់ ឈុនរ៉េត មិនយល់ថា ហេតុអីបានជីដូនមិនមានវត្តមាន នៅក្នុងផ្ទះ ។ រៀងរាល់ថ្ងៃ នៅពេលដែលចៅៗរបស់ ផាន់ ឈុនរ៉េត ចេញពីសាលារៀនក្មេងទាំងនោះតែងតែសួររកជីដូន និងប្រាប់ថា ខ្ញុំនឹកជីដូនខ្ញុំខ្លាំងណាស់។

## ឆេង លាភ



**អាសយដ្ឋាន:** ផ្ទះលេខ១៨២ដេ ផ្លូវលេខ៨០ ភូមិ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ
**អាយុ:** ៤៥ ឆ្នាំ
**ស្ថានភាពគ្រួសារ:** រៀបការ មានកូន៥នាក់ (ម្នាក់អាយុ ១៨ឆ្នាំ ១៣ឆ្នាំ ១២ឆ្នាំ ៥ឆ្នាំ និង២ឆ្នាំ) កូនបង ៣នាក់ កំពុងរៀននៅសាលា
**ឈ្មោះហៅក្រៅ:** យាយចេកចៀន
**មុខរបរ:** មេផ្ទះ
**ប័ណ្ណកម្មសិទ្ធិ:** មាន
**ការចោទប្រកាន់:** ក. បទកាន់កាប់ដោយខុសច្បាប់ លើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ខ. បទប្រឆាំងអាជ្ញាធរសាធារណៈ គ. បទជេរប្រមាថ និង ឃ. គំរាមសម្លាប់
**ថ្ងៃចាប់ខ្លួន:** ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២
**ថ្ងៃសវនាការ:** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
**វិនិច្ឆ័យទោស:** ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ២ឆ្នាំកន្លះ ដោយមានស្ថានទម្ងន់ទោស។

**កូនប្រុសឆេង លាភ ឈ្មោះកុល ពេជ្រ អាយុ១២ឆ្នាំ និយាយថា*"ខ្ញុំចង់ឲ្យម្ដាយខ្ញុំត្រលប់មកផ្ទះវិញ..."***

ឆេង លាភ អាយុ ៤៥ឆ្នាំ អ្នកស្រីគឺជាអ្នកដឹកនាំសំខាន់មួយរូបក្នុងការតវ៉ារបស់អ្នកបឹងកក់។ អ្នកស្រីឆេង លាភ គឺជាអ្នកជិតខាងរបស់ ទេព វន្នី ហើយក្រុមគ្រួសារអ្នកទាំងពីរនេះ តែង តែបានជួបពិភាក្សាគ្នា ដើម្បីរៀបចំសកម្មភាព និងយុទ្ធសាស្ត្ររបស់យុទ្ធនាការតវ៉ា។ ឆេង លាភ គឺជាអ្នកពូកែនិយាយ ចេះបញ្ចុះបញ្ចូលគេ ហើយចេះកៀងគងប្រមូលអ្នកបឹងកក់ឲ្យចូលរួមក្នុងយុទ្ធនាការដើម្បីតវ៉ាទាមទារសិទ្ធិកាន់កាប់ដីធ្លីវិញ។

ដើម្បីគាំទ្រការតវ៉ារបស់សហគមន៍ ឆេង លាភ និងស្វាមី ឈ្មោះ នួន ទឹម បានប្រើប្រាស់ម៉ូតូកង់បីរបស់ខ្លួន ដើម្បីជាមធ្យោបាយដឹងជញ្ជូនសម្ភារៈ និងអាហារសម្រាប់អ្នកតវ៉ា។ ឆេង លាភ បានចូលរួមក្នុងសកម្មភាពតវ៉ា តាំងពីឆ្នាំ២០០៧។ គាត់គឺជាសកម្មជនតវ៉ាយ៉ាងសកម្មមួយរូប តែគាត់តែងតែរួចផុតពីការចាប់ខ្លួន។

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ គឺជាថ្ងៃដែល ឆេង លាភ ត្រូវចាប់ខ្លួន ខណៈពេលដែលឆេង លាភចូលរួមតវ៉ាជាមួយប្អូនប្រុស និងកូនស្រីអាយុ៥ឆ្នាំ។ កូនស្រី៥ឆ្នាំនោះ បានឃើញផ្ទាល់លើភ្នែក នៅពេលដែលម្ដាយត្រូវបាននគរបាលចាប់អូស។ ក្រុមគ្រួសាររបស់ ឆេង លាភ មានការព្រួយ បារម្ភយ៉ាងខ្លាំងអំពីសុខទុក្ខរបស់គាត់ខណៈរស់នៅក្នុងពន្ធនាគារ ជាពិសេសបញ្ហាសុខភាព។

ឆេង លាភ បានមករស់នៅតំបន់បឹងកក់ ជាមួយស្វាមី ប្អូនប្រុស និងកូនទាំង ៥នាក់តាំងពីឆ្នាំ ២០០៣ មកម្ល៉េះ។ កូនពៅរបស់ ឆេង លាភ មានអាយុទើបតែ ២ឆ្នាំប៉ុណ្ណោះទេ។

## ហេង មុំ



**អាសយដ្ឋាន:** ផ្ទះលេខ៧៥ ផ្លូវលេខ៨៦ ភូមិ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ
**អាយុ:** ៤១ ឆ្នាំ
**ស្ថានភាពគ្រួសារ:** រៀបការ មានកូនស្រីម្នាក់ និងកូន ៦ នាក់របស់ស្វាមី (កូនរបស់ភរិយាមុន)
**ឈ្មោះហៅក្រៅ:**មុំ
**មុខរបរ:** មេផ្ទះ
**ប័ណ្ណកម្មសិទ្ធិ:** ត្រូវគេកាត់ចេញដោយបំពាន
**ការចោទប្រកាន់:** ជាប់ចោទ៥ករណី គឺ ក. បទជេរប្រមាថ ខ. គំរាមសម្លាប់ គ. បរិហារកេរ្តិ៍បទ ឃ. កាន់កាប់ ដោយខុសច្បាប់លើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ និង ង.បទប្រឆាំងអាជ្ញាធរសាធារណៈ
**ថ្ងៃចាប់ខ្លួន:** ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២
**ថ្ងៃសវនាការ:** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
**វិនិច្ឆ័យទោស:** ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ២ឆ្នាំកន្លះ ដោយមានស្ថានទម្ងន់ទោស

**ស្វាមីរបស់ហេង មុំ ឈ្មោះ សុខ គុងហេង បានមានប្រសាសន៍ថា *"គ្មានមូលហេតុអ្វីដែល សោះ ដែលត្រូវចាប់ហេង មុំ នាងគ្រាន់តែចូលរួមតវ៉ាទាមទារសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់របស់យើងតែប៉ុណ្ណោះ"***

ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ គឺជាថ្ងៃដែលហេង មុំ និងក្រុមគ្រួសារសម្លឹងមើលផ្ទះរបស់ខ្លួនដែលរស់នៅជាង១៨ឆ្នាំ ត្រូវបំផ្លាញទាំងស្រុង។ ក្រុមគ្រួសារ ហេង មុំមិនបានទទួលសំណងអ្វីទាល់តែសោះ។ បីខែក្រោយមក ស្វាមីរបស់ហេង មុំ ជាកម្មករសំណង់បានខ្ចីលុយខ្លះពីសាច់ញាតិ និងបានព្យាយាមសាងសង់ផ្ទះឡើងវិញលើដីដែលរងការបំផ្លាញ។

មុនពេលផ្ទះរបស់ហេង មុំ ត្រូវគេវាយបំផ្លាញ ប្តីប្រពន្ធទាំងពីរនាក់នេះ គឺជាអ្នកតវ៉ាយ៉ាងសកម្មដើម្បីសហគមន៍បឹងកក់។ ហេង មុំ ធ្លាប់ត្រូវបាននគរបាលចាប់ខ្លួនម្តង ប៉ុន្តែមិនត្រូវបានកាត់ទោសឡើយ។ ស្វាមីហេង មុំ ព្រួយបារម្ភយ៉ាងខ្លាំងចំពោះសុខភាពខាងផ្លូវកាយ និងផ្លូវចិត្ត ខណៈរស់នៅក្នុងពន្ធនាគារ។ នៅពេលដែលស្វាមី ហេង មុំ សួរសុខទុក្ខ ហេង មុំក្នុងពន្ធនាគារ គាត់បានសំគាល់ឃើញថា *"ហេង មុំ មានការភិតភ័យ ហើយចេះតែងាកមកមើលខាងក្រោយហាក់ដូចជាបារម្ភនឹងអ្វីម្យ៉ាង"*។ ហេង មុំ មានជម្ងឺពីមុនមក ហើយធ្លាប់ទទួលបានការប្រឹក្សាយោបល់ ដោយសារវិបត្តិផ្លូវចិត្តដោយសារបញ្ហាបឹងកក់។

កូនស្រីអាយុ១២ឆ្នាំ របស់ ហេង មុំទទួលរងការភិតភ័យតក់ស្លុតចំពោះការចាប់ និងកាត់ទោសរបស់ម្តាយ។ នាងមិនអាចប្រមូលអារម្មណ៍រៀនបានឡើយ។ ទោះជាយ៉ាងណាក៏ដោយនាងនិងឪពុកបានចូលរួមយ៉ាងសកម្មក្នុងការតវ៉ារឿងបឹងកក់។ ចំពោះនាង និងឪពុកការតវ៉ាតាំងនាមឲ្យហេង មុំ ជាភារកិច្ចមួយយ៉ាងសំខាន់។

## គង់ ចន្ថា



**អាសយដ្ឋានៈ** ផ្ទះលេខ៤៣ ផ្លូវលេខ៧០ ភូមិ២៤ សង្កាត់ស្រះចក ខណ្ឌដូនពេញ
**អាយុៈ** ៤១ ឆ្នាំ
**ស្ថានភាពគ្រួសារៈ** រៀបការ មានកូន៤នាក់ (ម្នាក់អាយុ ១៩ឆ្នាំ ១៧ឆ្នាំ ១៤ឆ្នាំ និង១២ឆ្នាំ) កូនទាំង៤នាក់កំពុងរៀននៅឡើយ
**ឈ្មោះហៅក្រៅៈ** គ្មាន
**មុខរបរៈ** មេផ្ទះ
**ប័ណ្ណកម្មសិទ្ធិៈ** មាន
**ការចោទប្រកាន់ៈ** ជាប់ចោទ៣ករណី គឺ ក. បទជេរប្រមាថ ខ. បទប្រឆាំងអាជ្ញាធរសាធារណៈ គ. គំរាមសម្លាប់និង ឃ. បទកាន់កាប់ដោយខុសច្បាប់លើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ
**ថ្ងៃចាប់ខ្លួនៈ** ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២
**ថ្ងៃសវនាការៈ** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
**វិនិច្ឆ័យទោសៈ** ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ២ឆ្នាំកន្លះ ដោយមានស្ថានទម្ងន់ទោស

*ស្វាមីគង់ ចន្ថា ឈ្មោះ សៀក ហេង បានមានប្រសាសន៍ថា "ខ្ញុំចង់ឲ្យស្ថានទូតបរទេសទាំងអស់ ដែលនៅស្រុកខ្មែរជួយសំនូមពរឲ្យរដ្ឋាភិបាលដោះលែងអ្នកបឹងកក់ទាំង១៥"*

គង់ ចន្ថា និងគ្រួសារ ក៏ធ្លាប់រងការរំលោភបំពានដីធ្លីពីមុនមកដែរ។ ផ្ទះរបស់គាត់នៅបឹងកក់ និងដីមួយកន្លែងនៅខេត្តព្រះវិហារ គឺសុទ្ធតែរងការរំលោភបំពានពីសំណាក់ទាហានកាលពីឆ្នាំ ២០០៤។

ក្រុមគ្រួសារ គង់ ចន្ថា រស់នៅតំបន់បឹងកក់តាំងពីឆ្នាំ២០០០។ នៅពេលជម្លោះដីចាប់ផ្តើមក្នុងឆ្នាំ២០០៧ ក្រុមគ្រួសារ គង់ ចន្ថា ព្រួយបារម្ភយ៉ាងខ្លាំង និងខ្លាចបាត់បង់ដីម្តងទៀត។ ដូច្នេះពួកគេត្រូវតែរកវិធានការជាបន្ទាន់។ គង់ ចន្ថា គឺជាអ្នកតវ៉ាដ៏សកម្មក្នុងយុទ្ធនាការទាមទារដីបឹងកក់។

មុនដំបូងស្វាមីរបស់គង់ ចន្ថា និងកូនទាំង៤នាក់ មិនមានការភិតភ័យឡើយ ពេលលឺថា គង់ ចន្ថាត្រូវគេចាប់ខ្លួនកាលពីថ្ងៃទី២២ ខែឧសភា។ ពីព្រោះតែ គង់ ចន្ថា ធ្លាប់ត្រូវបានគេចាប់ខ្លួន៤ដងរួចមកហើយ នៅពេលដែលចូលរួមបាតុកម្មអហិង្សា។ ក្រុមគ្រួសារ គង់ ចន្ថា បានស៊ាំទៅនឹងការឃ្លាំមើល និងបំភិតបំភ័យជារឿយៗរបស់នគរបាលទៅហើយ។ ប៉ុន្តែអ្វីដែលធ្វើឲ្យពួកគេតក់ស្លុត នោះគឺពេលលឺថា គង់ ចន្ថាត្រូវតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារនៅ២ថ្ងៃបន្ទាប់មក។

គង់ ចន្ថា មានបញ្ហាសុខភាពមួយចំនួនពីមុនមក ហើយធ្លាប់ទទួលបានការប្រឹក្សាយោបល់វិបត្តិផ្លូវចិត្តដោយសារបញ្ហាបឹងកក់។

## ចាន់ ណាវី



**អាសយដ្ឋាន:** ផ្ទះលេខ១១១ ផ្លូវលេខ៧០ ភូមិ២៤ សង្កាត់ស្រះចក ខណ្ឌដូនពេញ
**អាយុ:** ៥៧ ឆ្នាំ
**ស្ថានភាពគ្រួសារ:** រស់នៅជាមួយជាស្ត្រីជួន ម៉ាឌីណា និងកូន៦នាក់ (កូនក្មេះអាយុ២ឆ្នាំ និងកូនអាយុ ១០ ឆ្នាំ ១៦ឆ្នាំ ១៨ឆ្នាំ និង២០ឆ្នាំ)
**ឈ្មោះហៅក្រៅ:** គ្មាន
**មុខរបរ:** មេផ្ទះ
**ប័ណ្ណកម្មសិទ្ធិ:** មាន
**ការចោទប្រកាន់:** ក.បទកាន់កាប់ ដោយខុសច្បាប់លើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ខ.បទប្រឆាំងអាជ្ញាធរសាធារណៈ
**ថ្ងៃចាប់ខ្លួន:** ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២
**ថ្ងៃសវនាការ:** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
**វិនិច្ឆ័យទោស:** ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ២ឆ្នាំកន្លះ (ព្យួរទោស ៦ខែ)

**ជួន ម៉ាឌីណា មិត្តភ័ក្តរបស់ចាន់ ណាវី បានមានប្រសាសន៍ថា *"កូនក្មេះពីរនាក់ដឹងថា ជីដូន នៅក្នុងពន្ធនាគារ ប៉ុន្តែខ្ញុំបានប្រាប់ថា ជីដូននឹងត្រលប់មកផ្ទះវិញឆាប់ៗនេះ..... នៅពេលយប់ ក្មេងពីរនាក់នេះតែងតែសួររកជីដូនពេលភ្ញាក់ឡើង"***

ចាន់ ណាវី រស់នៅបឹងកក់ជាមួយ អ្នកស្រីជួន ម៉ាឌីណា តាំងពីឆ្នាំ១៩៩០មកម្លេះ។ ចាន់ ណាវីបានចូលរួមតវ៉ាតាំងពីឆ្នាំ២០០៧ សំណាងល្អមិនដែលត្រូវបាននគរបាលចាប់ពីមុនមកឡើយ។

ចាន់ ណាវី និងជួន ម៉ាឌីណា គឺជាបង្គោលគ្រួសារត្រូវថែទាំក្មេងៗ ទាំង៦នាក់រួមទាំងកូនក្មេះទាំងពីរ ដែលត្រូវជាចៅរបស់ចាន់ ណាវី។ ពេលចូលរួមតវ៉ា ចាន់ ណាវី តែងយកកូនក្មេះទាំងពីរទៅជាមួយជានិច្ច។ ក្មេងទាំងពីរនេះ នៅក្រោមអាណាព្យាបាលរបស់ ចាន់ ណាវី និងជួន ម៉ាឌីណា តាំងពីអាយុ២ខែមកម្លេះ។ ក្មេងទាំងពីរនេះក៏នៅក្នុងព្រឹត្តការណ៍នៅថ្ងៃ ចាន់ ណាវី ត្រូវនគរបាលចាប់ខ្លួនដែរ។

នៅថ្ងៃនោះអ្នកជិតខាងបាននាំក្មេងទាំងពីរមកផ្ទះវិញ និងបានទូរស័ព្ទទៅជួន ម៉ាឌីណា ប្រាប់រឿងចាប់ខ្លួនចាន់ ណាវី (ជួន ម៉ាឌីណា ជាគ្រូបង្រៀនពេញម៉ោង) ។ សព្វថ្ងៃនេះ ជួន ម៉ាឌីណា បានរៀបចំពេលវេលា ថែទាំងក្មេងៗ និងទៅធ្វើការពេញម៉ោងទៀត ហើយ ឌីណា ក៏ចូលរួមសកម្មភាពតវ៉ាដោយផ្ទាល់ផងដែរ ហើយកូនក្មេះទាំងពីរក៏នៅតែទៅតាមដដែល។

ក្រុមគ្រួសារមួយនេះ ពិតជាព្រួយបារម្ភចំពោះសុខភាពរបស់ ចាន់ ណាវី ដែលមានជម្ងឺតាំងពីមិនទាន់ជាប់ពន្ធនាគារម្លេះ ហើយពេលនេះជម្ងឺគាត់កាន់តែធ្ងន់ទៅៗ។

## បូវ សោភា




**អាសយដ្ឋាន:** ផ្ទះលេខ១៦៣ ផ្លូវលេខ៨០ ភូមិ២១ សង្កាត់ស្រះចក ខណ្ឌដូនពេញ
**អាយុ:** ៣៦ ឆ្នាំ
**ស្ថានភាពគ្រួសារ:** រៀបការមានកូន៣នាក់ (ម្នាក់អាយុ ៨ឆ្នាំ ១៩ឆ្នាំ និង១៧ឆ្នាំ)
**ឈ្មោះហៅក្រៅ:**ស្រីនាង
**មុខរបរ:** មេផ្ទះ
**ប័ណ្ណកម្មសិទ្ធិ:** មាន
**ការចោទប្រកាន់:** ក.បទកាន់កាប់ដោយខុសច្បាប់លើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ
ខ.បទប្រឆាំងអាជ្ញាធរសាធារណៈ
**ថ្ងៃចាប់ខ្លួន:** ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២
**ថ្ងៃសវនាការ:** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
**វិនិច្ឆ័យទោស:** ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ២ឆ្នាំកន្លះ ដោយមានស្ថានទម្ងន់ទោស

**កូនស្រី បូវ សោភា ឈ្មោះ លី ហេងលាភ អាយុ១៩ឆ្នាំ រៀបរាប់ថា** ***"ពេលម្តាយត្រូវចាប់ខ្លួន ខ្ញុំពិតជាបារម្ភពីម្តាយណាស់ ខ្ញុំគេងអត់លក់ ញុំាអត់បាន។ ខ្ញុំខ្លាចថា នគរបាលវ៉ៃម្តាយខ្ញុំ"***

បូវ សោភា ចាប់ខ្លួន នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២។ ក្នុងក្រុមគ្រួសារ បូវ សោភា មានតែ បូវ សោភា ម្នាក់ឯងទេដែលបានចូលរួមតវ៉ាជាមួយអ្នកបឹងកក់។ បងស្រី បូវ សោភា ឈ្មោះ បូវ សោភ័ណ្ឌ បានលឺថាមានវត្តមាននគរបាលច្រើនណាស់នៅកន្លែងតវ៉ា។ បូវ សោភ័ណ្ឌ មានការបារម្ភពីសុវត្ថិភាពក៏បានទូរស័ព្ទទៅ បូវ សោភា។ សម្លេងបូវ សោភា ជាធម្មតា និងប្រាប់ បូវ សោភ័ណ្ឌ ថាកុំឲ្យបារម្ភដោយសារមិនមានរឿងអ្វីនោះទេ។ មិនយូរប៉ុន្មាន បូវ សោភ័ណ្ឌដឹងពីអ្នកជិតខាងម្នាក់ថា បូវ សោភា ត្រូវនគរបាលចាប់ខ្លួនហើយ។

បូវ សោភា និងក្រុមគ្រួសារបានមករស់នៅបឹងកក់តាំងពីឆ្នាំ១៩៩៤។ នាងក៏ជាអ្នកតវ៉ាសកម្មមួយរូបតាំងពីឆ្នាំ២០០៧ មកម្លេះ។ បូវ សោភា ជាអ្នកអង់អាច ដែលចេញមុខជួយជ្រោមជ្រែងក្រុមគ្រួសារអ្នកបឹងកក់ណាដែលមិនបានទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី។ ចាប់តាំងពី បូវ សោភា ត្រូវចាប់ខ្លួនមកកូនៗ និងបងស្រីបានក្លាយជាអ្នកតវ៉ាយ៉ាងសកម្ម។

ក្រុមគ្រួសារ បូវ សោភា បានទៅសួរសុខទុក្ខនាងក្នុងពន្ធនាគារបានពីរបីដងដែរ។ ការជួបដំបូងបានត្រឹមតែ១០នាទីទេ។ ពួកគេព្រួយបារម្ភយ៉ាងខ្លាំងពីសុខភាព បូវ សោភា ដោយហេតុតែបូវ សោភាត្រូវការលេបថ្នាំជាប្រចាំ។

## ងួន គឹមឡាង



**អាសយដ្ឋាន:** ផ្ទះលេខ៨៣ ផ្លូវលេខ៧០ ភូមិ២១ សង្កាត់ស្រះចក ខណ្ឌដូនពេញ
**អាយុ:** ៥៤ ឆ្នាំ
**ស្ថានភាពគ្រួសារ:** លែងលះ មានកូនម្នាក់អាយុ១៦ឆ្នាំ
**ឈ្មោះហៅក្រៅ:** គ្មាន
**មុខរបរ:**លក់ដូរតាមផ្លូវ
**ប័ណ្ណកម្មសិទ្ធិ:** មាន
**ការចោទប្រកាន់:** ក. បទកាន់កាប់ដោយខុសច្បាប់លើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ខ. បទប្រឆាំងអាជ្ញាធរសាធារណៈ
**ថ្ងៃចាប់ខ្លួន:** ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២
**ថ្ងៃសវនាការ:** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
**វិនិច្ឆ័យទោស:** ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ២ ឆ្នាំកន្លះ (ព្យួរទោស៦ខែ)

**កូនប្រុសងួន គឹមឡាង ឈ្មោះ ខៀវ ពេជ្រសង្ហា អាយុ ១៦ឆ្នាំ និយាយថា** *"ខ្ញុំនឹកម្តាយខ្ញុំណាស់ ម្តាយតែងតែប្រាប់ខ្ញុំថា អត់អីទេ តែខ្ញុំឃើញម្តាយខ្ញុំដូចជាស្គមជាងមុន ហើយមានបញ្ហាស្បែក"*

ងួន គឹមឡាង និងក្រុមគ្រួសារបានមករស់នៅបឹងកក់តាំងពីឆ្នាំ១៩៧៩។ ក្នុងផ្ទះមានគ្នា៧នាក់ គឺ ងួន គឹមឡាង កូនប្រុស ក្មួយស្រីរបស់ស្វាមី និងកូន ៣នាក់របស់អតីតស្វាមី។ ងួន គឹមឡាង បានលែងលះជាមួយស្វាមី។

ងួន គឹមឡាង បានចូលរួមតវ៉ាជាមួយអ្នកបឹងកក់តាំងពីឆ្នាំ២០០៧ មកម្លេះ។ ប៉ុន្តែថ្មីៗគាត់ទើបតែចេញមុខសកម្ម ហើយបានចូលរួមគ្រប់សកម្មភាពតវ៉ាទាំងអស់។ ងួន គឹមឡាង ពិបាកក្នុងការដើរហើរដោយសារគាត់មានជម្ងឺលើសឈាម ដូចនេះគាត់មិនសូវចេញមុខតវ៉ាឡើយ។ ងួន គឹមឡាង មិនធ្លាប់ចាប់ខ្លួនពីមុនមកទេ។

ក្មួយស្រីរបស់ ងួន គឹមឡាង ឈ្មោះ សុខ ចាន់ថន បានលឺថា មានវត្តមាននគរបាលជាច្រើននៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២។ នាងបានទូរស័ព្ទទៅ ងួន គឹមឡាង ដើម្បីសួរពីសុវត្ថិភាព ប៉ុន្តែ ងួន គឹមឡាងប្រាប់ថា គាត់សុខសប្បាយទេ ដោយគាត់ទើបត្រលប់មកពីតវ៉ា ដូច្នេះកុំបារម្ភអី រួច ងួន គឹមឡាង ក៏បិទទូរស័ព្ទទៅ។ នៅម៉ោងជាង ១២ថ្ងៃត្រង់ ថ្ងៃដដែល ងួន គឹមឡាង បានទូរស័ព្ទមក សុខ ចាន់ថន ប្រាប់ថា គាត់ត្រូវនគរបាលចាប់ខ្លួនហើយ។

ពេលទៅសួរសុខទុក្ខ ងួន គឹមឡាងក្នុងពន្ធនាគារ ក្រុមគ្រួសារសម្គាល់ថា ងួន គឹមឡាង ហាក់ដូចជានៅក្លាហាន ប៉ុន្តែយ៉ាងណាក៏ដោយក្រុមគ្រួសារពិតជានៅព្រួយបារម្ភអំពីសុខភាពងួន គឹមឡាង ពីព្រោះ គឹម ឡាងត្រូវការថ្នាំជាប្រចាំ។ ងួន គឹមឡាងបានផ្តាំក្រុមគ្រួសារមិនបាច់មកសួរសុខទុក្ខញឹកញាប់ពេកដោយសារតែមកម្តងៗត្រូវចំណាយលុយច្រើន។

# សួង សម័យ



**អាសយដ្ឋាន:** ផ្ទះលេខ២៦ ផ្លូវលេខ៨៦ ភូមិ ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ
**អាយុ:** ៥៣ ឆ្នាំ
**ស្ថានភាពគ្រួសារ:** មេម៉ាយ មានកូនប្រុស ២ នាក់ (ម្នាក់អាយុ១៨ឆ្នាំ និង២៦ឆ្នាំ)
**ឈ្មោះហៅក្រៅ:** គ្មាន
**មុខរបរ:** មេផ្ទះ
**ប័ណ្ណកម្មសិទ្ធិ:**ត្រូវគេកាត់ចេញដោយបំពាន
**ការចោទប្រកាន់:** ក. បទកាន់កាប់ដោយខុសច្បាប់លើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ខ. បទប្រឆាំងអាជ្ញាធរសាធារណៈ
**ថ្ងៃចាប់ខ្លួន:** ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២
**ថ្ងៃសវនាការ:** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
**វិនិច្ឆ័យទោស:** ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ២ឆ្នាំកន្លះ (ព្យួរទោស៦ខែ)

**យិន សឿនសុផាត អាយុ២៦ឆ្នាំ ជាកូនប្រុស សួង សម័យ បានប្រកាសថា "*បើយើងមិនចូលរួមតវ៉ាទេ យើងមុខជាគ្មានវាសនាបានដីយើងត្រលប់មកវិញឡើយ*"**

សួង សម័យ អាយុ៥៣ឆ្នាំ បានមករស់នៅបឹងកក់ជាមួយស្វាមី និងកូនពីរនាក់តាំងពីឆ្នាំ ១៩៩៣។ សួង សម័យ ចាប់ផ្តើមចូលរួមតវ៉ាតាំងពីឆ្នាំ២០០៧ ហើយធ្លាប់នគរបាលចាប់ខ្លួន២ ដង តែមិនបានកាត់ទោសទេ។

ស្វាមីរបស់សួង សម័យ មិនធ្លាប់ចូលរួមសកម្មភាពតវ៉ាឡើយ ដោយសារគាត់មានជម្ងឺ។ ស្វាមីសួង សម័យបានទទួលមរណៈភាពកាលពីឆ្នាំ២០១១។ ទោះបីជាស្វាមីបានស្លាប់បាត់ទៅ ហើយក៏សួង សម័យ នៅតែបន្តចូលរួមតវ៉ាដើម្បីជួយអ្នកបឹងកក់ និងដើម្បីទាមទារដីរបស់ខ្លួនមកវិញដែរ។

កូនប្រុសច្បងរបស់ សួង សម័យ ឈ្មោះ យិន សឿនសុផាត គឺជាអ្នករាប់រងទទួលបន្ទុកគ្រួសារ។ ដែលធ្វើការ ៦ថ្ងៃក្នុងមួយសប្តាហ៍ជាអ្នករត់តុ។ តាំងពីម្តាយ ត្រូវចាប់ខ្លួន យិន សឿនសុផាត ដើរតួនាទីមើលថែប្អូនប្រុស ដាំបាយ និងរៀបចំទុកដាក់ផ្ទះសម្បែង។ តាំងពីនោះមក សឿនសុផាត អាចទៅធ្វើការបានត្រឹមតែ ២ ឬ ៣ថ្ងៃប៉ុណ្ណោះ ក្នុងមួយអាទិត្រ។ នៅពេលទំនេរ យិន សឿនសុផាតតែងចូលរួមតវ៉ាជាមួយអ្នកបឹងកក់ជំនួសមុខឲ្យម្តាយរបស់ខ្លួន។

នៅថ្ងៃដែលសួង សម័យ ត្រូវបានគេចាប់ខ្លួន មិត្តភ័ក្តិសឿនសុផាត បានទូរស័ព្ទមកប្រាប់ដំណឹងពីការចាប់ខ្លួនម្តាយ។ ពេលដែលសឿនសុផាត និងប្អូនប្រុសបានទៅសួរសុខទុក្ខម្តាយនៅពន្ធនាគារ។ អ្នកទាំងពីឃើញថា ម្តាយខ្លួនមើលទៅខ្សោយ ដូចជាមិនបានទទួលទានអាហារគ្រប់គ្រាន់។ សួង សម័យ ក៏មានជម្ងឺប្រចាំកាយដែរ។

## **តុល ស្រីពៅ**



**អាសយដ្ឋាន:** ផ្ទះលេខ៤៩ ផ្លូវលេខ៧០ ភូមិ២៤ សង្កាត់ស្រះចក ខណ្ឌដូនពេញ
**អាយុ:** ៣៥ ឆ្នាំ
**ស្ថានភាពគ្រួសារ:** រៀបការ មានកូន៣នាក់ (ម្នាក់អាយុ៥ឆ្នាំ ៩ឆ្នាំ និង១១ឆ្នាំ)
**ឈ្មោះហៅក្រៅ:** ពៅ
**មុខរបរ:** មេផ្ទះ
**ប័ណ្ណកម្មសិទ្ធិ:** មាន
**ការចោទប្រកាន់:** ជាប់ចោទ ក. ជេរប្រមាថ ខ.គំរាមសម្លាប់ គ. បទកាន់កាប់ដោយខុសច្បាប់លើអចលនវត្ថុ របស់នីតិបុគ្គលសាធារណៈ និងឃ. បទប្រឆាំងអាជ្ញាធរសាធារណៈ
**ថ្ងៃចាប់ខ្លួន:** ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២
**ថ្ងៃសវនាការ:** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
**វិនិច្ឆ័យទោស:** ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ២ឆ្នាំកន្លះ ដោយមានស្ថានទម្ងន់ទោស

**ប៉ោ សុគណ្ណកញ្ញា អាយុ១១ឆ្នាំ ជាកូនស្រី តុល ស្រីពៅ បានប្រកាសថា *"ខ្ញុំប្រាប់ខ្លួនឯងថា ត្រូវតែរឹងមាំ និងក្លាហាន។ ខ្ញុំត្រូវតែពុះពារ បើមិនអញ្ចឹងទេ គ្មានថ្ងៃដែលម្តាយខ្ញុំបានរួចខ្លួនមានសេរីភាព មកវិញឡើយ"***

នៅពេលដែលកូនស្រីច្បងរបស់ តុល ស្រីពៅ បានលឺដំណឹងដំបូងពីអ្នកជិតខាងថា ម្តាយត្រូវគេចាប់ខ្លួនទៀតហើយ នាងមិនមានការបារម្ភទេ ពីព្រោះ តុល ស្រីពៅ គឺជាអ្នកតវ៉ាសកម្មឲ្យសហគមន៍បឹងកក់ ហើយធ្លាប់ត្រូវនគរបាលចាប់ខ្លួន២ដងរួចមកហើយ ប៉ុន្តែមិនធ្លាប់ឃាត់ខ្លួនលើសពី១ថ្ងៃទេ។

ក្រោយ២ថ្ងៃកន្លងមក នាងបានយល់ថា ម្តងនេះ មុខជាខុសពីលើកមុនៗ។ ឪពុករបស់នាងដឹងថា លើកនេះធ្ងន់ធ្ងរ ប៉ុន្តែគាត់មិនបានប្រាប់កូនៗឲ្យដឹងឡើយ។

នៅថ្ងៃទីបី ប៉ោ សុគណ្ណកញ្ញា បានដឹងពីអ្នកជិតខាងថា ម្តាយត្រូវតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារ២ឆ្នាំកន្លះ។ នាងនិយាយថា *"ខ្ញុំយំហើយយំទៀត ហើយខ្ញុំដើរទៅផ្ទះប្រាប់ប្អូនប្រុសប្អូនស្រីខ្ញុំ។ យើងយំទាំងអស់គ្នា តែក្រោយមកយើងឈប់យំ ដោយសារយើងមិនចង់ឲ្យលោកឪពុកពិបាកចិត្ត។"*

ចាប់តាំងពីម្តាយត្រូវចាប់ខ្លួន នាងបានចេញមុខយ៉ាងសកម្មក្នុងការតវ៉ាជាមួយអ្នកបឹងកក់ និងចេញមុខនិយាយជាសាធារណៈទៀតផង។ នាងនិយាយថា *"រស់នៅគ្មានម្តាយ ដូចរស់នៅក្នុងផ្ទះអត់ដំបូលអញ្ចឹង"*។

## ទេព វន្នី



**អាសយដ្ឋាន:** ផ្ទះលេខ១៨១បេ ផ្លូវលេខ៨៦ ភូមិ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ
**អាយុ:** ៣១ ឆ្នាំ
**ស្ថានភាពគ្រួសារ:** រៀបការ មានកូន២នាក់ (កូនប្រុសអាយុ៧ឆ្នាំ និងកូនស្រីអាយុ៩ឆ្នាំ)
**ឈ្មោះហៅក្រៅ:** ស្រីមៅ
**មុខរបរ:** មេផ្ទះ
**ប័ណ្ណកម្មសិទ្ធិ:** មាន
**ការចោទប្រកាន់:** ក. ជេរប្រមាថ ខ. គំរាមសម្លាប់ គ. បរិហារកេរ្តិ៍ ឃ. បទកាន់កាប់ ដោយខុសច្បាប់លើអចលនវត្ថុរបស់នីតិបុគ្គល សាធារណៈ ង. បទប្រឆាំងអាជ្ញាធរសាធារណៈ
**ថ្ងៃចាប់ខ្លួន:** ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២
**ថ្ងៃសវនាការ:** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
**វិនិច្ឆ័យទោស:** ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ២ឆ្នាំកន្លះ ដោយមានស្ថានទម្ងន់ទោស

***លោក អ៊ូ គង់ជា ស្វាមី ទេព វន្នី មានប្រសាសន៍ថា "យើងចង់ប្រាប់ពិភពលោកនូវអ្វីដែលកំពុងកើតមាន!"***

ទេព វន្នី គឺជាកំលាំងមួយដ៏ខ្លាំងសំរាប់យុទ្ធនាការតវ៉ាអ្នកបឹងកក់។ ទេព វន្នី ត្រូវគេធ្លាប់ចាប់ខ្លួនជាច្រើនលើកច្រើនសារមកហើយ ប៉ុន្តែមិនដែលបានកាត់ទោសទេ។ ក្រុមគ្រួសារនាងបានមករស់នៅបឹងកក់តាំងពីឆ្នាំ២០០៤។

ពីរ បីថ្ងៃមុនចាប់ខ្លួន ១៨គ្រួសារពីអ្នកភូមិ១ បឹងកក់បានស្នើឲ្យ ទេព វន្នី ជួយគាំទ្រ និង ឃ្លាំមើលគម្រោងតវ៉ាថ្ងៃទី២២ ខែឧសភា ផង។ ពេលនោះ ទេព វន្នី បានប្រមូលអ្នកបឹងកក់ឲ្យចូលរួមតវ៉ា និងឃ្លាំមើល ប្រសិនមានករណីហិង្សា ឫគំរាមកំហែងមកលើអ្នកតវ៉ា។ ស្វាមីរបស់ ទេព វន្នី ក៏ចូលរួមដែរ ហើយបានថតវីដេអូទុកផងដែរ។

នៅម៉ោងប្រហែល ១០ព្រឹក ស្វាមី ទេព វន្នី បានចេញទៅធ្វើការ។ មួយម៉ោងក្រោយមកនាងបានទូរស័ព្ទទៅស្វាមីប្រាប់ថា នាងត្រូវបានគេចាប់ខ្លួនហើយ។ លោក អ៊ូ គង់ជា មិនបានប្រាប់រឿងនេះឲ្យកូនៗដឹងឡើយ រហូតទាល់តែដល់ថ្ងៃទី២៤ ខែឧសភា ជាថ្ងៃដែល ទេព វន្នីត្រូវតុលាការកាត់ទោសទើបកូនៗបានដឹង។

នេះមិនមែនជាលើកទី១ឡើយ ដែល ទេព វន្នី និងស្វាមីចូលរួមតវ៉ាទាមទារដីធ្លីលើជីជម្លោះជាមួយអាជ្ញាធរ។ ក្រុមគ្រួសារនេះ ធ្លាប់បាត់បង់ដីរបស់ខ្លួនស្ថិតនៅក្នុងឃុំអមទ្បាំង ខេត្តកំពង់ស្ពឺ ដែលកាលណោះ ដីជម្លោះកើតឡើងរវាងប្រជាពលរដ្ឋ និងក្រុមហ៊ុនចំការអំពៅរបស់លោកឧកញ៉ា លី យ៉ុងផាត់។

ចាប់តាំងពី ទេព វន្នី ត្រូវគេចាប់ខ្លួន។ លោក គង់ជាបានដើរតួយ៉ាងសកម្មក្នុងការដឹកនាំការតវ៉ារបស់អ្នកភូមិបឹងកក់។

## ថូ ដាវី



**អាសយដ្ឋាន:** ផ្ទះលេខ១៣៩បេ ផ្លូវលេខ៨៦ ភូមិ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ
**អាយុ:** ២៥ ឆ្នាំ
**ស្ថានភាពគ្រួសារ:**រៀបការ មានកូន២នាក់ (ម្នាក់អាយុ៤ឆ្នាំ និង៦ឆ្នាំ)
**ឈ្មោះហៅក្រៅ:**មុំ
**មុខរបរ:** អ្នករត់តុ
**ប័ណ្ណកម្មសិទ្ធិ:** មាន
**ការចោទប្រកាន់:**ក. បទកាន់កាប់ដោយខុសច្បាប់លើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ខ.បទប្រឆាំងអាជ្ញាធរសាធារណៈ
**ថ្ងៃចាប់ខ្លួន:** ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២
**ថ្ងៃសវនាការ:** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
**វិនិច្ឆ័យទោស:** ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ២ឆ្នាំកន្លះ (ព្យួរទោស៦ខែ)

**ម្តាយ ថូ ដាវី ឈ្មោះ ឃិន ទូច មានប្រសាសន៍ថា** ***"មុនពេលយើងទទួលបានប្លង់ដី អ្នកភូមិជាច្រើនបានចូលរួមគាំទ្រយើង។ ឥឡូវយើងចង់ជួយពួកគេវិញ"***

ថូ ដាវី មានអាយុ២៥ឆ្នាំ។ នាង និងក្រុមគ្រួសារនាង ធ្លាប់ចូលរួមយ៉ាងសកម្មជាង ៣ឆ្នាំមក ហើយក្នុងការតវ៉ាដីធ្លីជាមួយអ្នកបឹងកក់។ នាងតែងតែចូលរួមតវ៉ាជាមួយ ម្តាយ ស្វាមី និងប្អូនប្រុសរបស់ជាប្រចាំជាមួយអ្នកបឹងកក់។

ក៏ប៉ុន្តែនៅថ្ងៃចាប់ខ្លួន ថូ ដាវី បានទៅចូលរួមតែម្នាក់ឯងប៉ុណ្ណោះទេ។ ក្រុមគ្រួសារនាងបានដឹងពីការចាប់ខ្លួននាងនៅពេលអ្នកជិតខាងបានមកផ្តល់ព័ត៌មាន។ ដំបូងម្តាយ ថូ ដាវី មានការស្ទាក់ស្ទើរមិនចង់ប្រាប់ចៅពីនាក់ពីរឿងចាប់ខ្លួនរបស់ ថូ ដាវីទេ ដោយប្រាប់ចៅទាំងពីរនាក់ថា ម្តាយជាប់ទៅធ្វើការ។ ប៉ុន្តែក្មេងទាំងពីរនាក់ បាន ដឹងពីរឿងចាប់ខ្លួនម្តាយតាមរយៈអ្នកជិតខាង។

ថូ ដាវី រស់នៅជាមួយម្តាយចាស់ ស្វាមី និងកូន២នាក់។ ក្រុមគ្រួសារនេះបានរស់នៅ បឹងកក់តាំងពីឆ្នាំ១៩៩៤។ ថូ ដាវី ធ្វើការជាអ្នករត់តុ ហើយក៏ជាអ្នករ៉ាប់រងគ្រួសារទាំងមូល ប៉ុន្តែ ក្រោយពីចាប់ខ្លួនមកក្រុមគ្រួសារមួយនេះ រងនូវការលំបាកយ៉ាងខ្លាំង។

ពេលទៅសួរសុខទុក្ខក្នុងពន្ធនាគារ ម្តាយ ថូ ដាវី សង្កេតឃើញថា នាងមានសភាពស្លេក ស្លាំង។ ថូ ដាវី ប្រាប់ថា នាងមិនអាចទទួលទានដំណេក និងទទួលទានអាហារបានស្រួលឡើយ ប៉ុន្តែនាងជម្រាបទៅម្តាយថា កុំឲ្យបារម្ភ ហើយឲ្យម្តាយនាងជួយមើលថែកូនៗនាងផង។

## សុខ ស្រីលាភ



**អាសយដ្ឋាន:** ផ្ទះលេខ២១៥ ផ្លូវលេខ៨៦ ភូមិ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ
**អាយុ:** ២៤ ឆ្នាំ
**ស្ថានភាពគ្រួសារ:** នៅលីវ មានបងប្អូន៥នាក់
**ឈ្មោះហៅក្រៅ:** គ្មាន
**មុខរបរ:** អ្នកសំអាត (មុនចាប់ខ្លួនបានឈប់ធ្វើការ)
**ប័ណ្ណកម្មសិទ្ធិ:** មាន
**ការចោទប្រកាន់:** ក. បទកាន់កាប់ដោយខុសច្បាប់លើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ខ.បទប្រឆាំងអាជ្ញាធរសាធារណៈ
**ថ្ងៃចាប់ខ្លួន:** ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២
**ថ្ងៃសវនាការ:** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
**វិនិច្ឆ័យទោស:** ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ២ឆ្នាំកន្លះ (ព្យួរទោស៦ខែ)

**អៀង ប៊ុនណ្ណារី ជាម្តាយ សុង ស្រីលាភ មានប្រសាសន៍ថា *"ខ្ញុំត្រូវតែក្លាហាន និងបន្តយុទ្ធនាការក្នុងតវ៉ាតទៅទៀត"***

សុង ស្រីលាភ គឺជាកូនស្រីពៅក្នុងគ្រួសារ។ នាងមិនសូវមានគេស្គាល់ច្រើនក្នុងចំណោម អ្នកជាប់ពន្ធនាគារទាំង១៥នាក់នោះទេ ហើយធ្លាប់ចូលរួមតវ៉ា ប៉ុន្តែមិនសូវសកម្មទេ។ ម្តាយនាងទេដែលជាអ្នកតវ៉ាយ៉ាងសកម្ម។ ទាំងពីរនាក់ម្តាយកូនមិនត្រូវបានគេចាប់ខ្លួនពីមុនមកទេ។

នៅថ្ងៃទី២២ ខែឧសភា អៀង ប៊ុនណ្ណារី មិនសូវស្រួលខ្លួន ដូចនេះ សុង ស្រីលាភ បានចូលរួមតវ៉ាម្នាក់ឯង។ ក្នុងពេលតវ៉ា សុង ស្រីលាភ មិនត្រូវបានចាប់ខ្លួនទេ តែនៅពេលចប់ព្រឹត្តិការណ៍តវ៉ា ខណៈពេលនាងដើរត្រលប់មកផ្ទះវិញ នាងក៏ត្រូវបាននគរបាលចាប់ខ្លួនតែម្តង។ អ្នកតវ៉ាដទៃទៀតយល់ថា សុង ស្រីលាភ ត្រូវចាប់ខ្លួន ដោយសារតែនាងមានការតតាំងជាមួយនគរបាលដែលព្យាយាមដកហូតយកមេក្រូពីអ្នកតវ៉ាផ្សេងទៀត។

នៅម៉ោងជាង ១២ថ្ងៃត្រង់ អៀង ប៊ុនណ្ណារី បានទទួលទូរស័ព្ទពីកូនស្រីប្រាប់ថា នាងត្រូវ បានចាប់ខ្លួនហើយ។ ពេលទៅសួរសុខទុក្ខក្នុងពន្ធនាគារ អៀង ប៊ុនណ្ណារី សម្គាល់ឃើញថា កូនស្រី ភ័យខ្លាចខ្លាំងណាស់។ សុង ស្រីលាភ បានត្អូញត្អែរអំពីការខ្វះខាត និងលំបាកទទួលទានដំណេក ក្នុងបន្ទប់ពន្ធនាគារ។

សុង ស្រីលាភ ជាអ្នករ៉ាប់រងក្នុងការរកប្រាក់បង់ថ្លៃមហាវិទ្យាល័យឲ្យប្អូនប្រុសម្នាក់ ដែលអាយុ២២ឆ្នាំ។ តាំងពីសុង ស្រីលាភ ត្រូវចាប់ខ្លួនថ្លៃសាលានៅមិនទាន់បង់នៅឡើយ។

## ង៉ែត យុន



**អាសយដ្ឋាន:** ផ្ទះលេខ៤៧ ផ្លូវលេខ៨៦ ភូមិ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ
**អាយុ:** ៧២ ឆ្នាំ
**ស្ថានភាពគ្រួសារ:** មានកូន៧នាក់ចេញធ្វើការទាំងអស់គ្នា និងមានចៅ៣នាក់ (ពីរនាក់អាយុ៦ឆ្នាំ និងម្នាក់ទៀតអាយុ១០ឆ្នាំ)
**ឈ្មោះហៅក្រៅ:** យាយមុំមី
**មុខរបរ:** មេផ្ទះ
**ប័ណ្ណកម្មសិទ្ធិ:** ត្រូវគេកាត់ចេញដោយបំពាន
**ការចោទប្រកាន់:** ក.បទកាន់កាប់ ដោយខុសច្បាប់លើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ខ.បទប្រឆាំងអាជ្ញាធរសាធារណៈ
**ថ្ងៃចាប់ខ្លួន:** ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២
**ថ្ងៃសវនាការ:** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
**វិនិច្ឆ័យទោស:** ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ២ឆ្នាំកន្លះ (ព្យួរទោស១៨ខែ)

***អេង ហ៊ុយ កូនស្រី ង៉ែត យុន បានប្រកាសថា "យើងមិនបានធ្វើអ្វីខុសទាល់តែសោះ ហេតុអ្វី បានជាពួកគេមកចាប់យើង? ហេតុអ្វីបានជាមកចាប់អ្នកដែលអត់មានកំហុសទៅវិញ?"***

ង៉ែត យុន អាយុ ៧២ឆ្នាំ គឺជាអ្នកតវ៉ានៅបឹងកក់ ដែលមានវ័យចំនាស់ជាងគេ ក្នុងចំណោមអ្នកតវ៉ាទាំង ១៥ នាក់ ដែលត្រូវបានគេចាប់ខ្លួន។ ង៉ែត យុន បានមករស់នៅបឹងកក់តាំង ពីឆ្នាំ២០០៥ ហើយបានសកម្មក្នុងយុទ្ធនាការតវ៉ាតាំងពីឆ្នាំ២០០៧។

ក្រុមគ្រួសាររបស់ ង៉ែត យុន មានគ្នា១០នាក់ រួមមាន ង៉ែត យុន ស្វាមី កូនប្រុសស្រី៥នាក់ (កូនសរុប៧នាក់) និងចៅ៣នាក់។ ស្វាមី ង៉ែត យុន មានអាយុ ៨៥ឆ្នាំ ដោយសារគាត់ចាស់ និងមានជម្ងឺ គាត់កម្រចេញពីផ្ទះណាស់ ប៉ុន្តែគាត់តាមដានព័ត៌មានរាល់ថ្ងៃ ហើយសង្ឃឹមថា ប្រពន្ធគាត់នឹងត្រូវបានគេដោះលែងក្នុងពេលឆាប់ៗនេះ។

ថ្ងៃទី២២ ខែឧសភា ង៉ែត យុន បានទូរស័ព្ទមកប្រាប់កូនស្រីថា គាត់ត្រូវគេចាប់ខ្លួនហើយ។ ប្រហែលម៉ោង៨យប់ កូនស្រីគាត់បានទៅជួបគាត់នៅស្នងការប្រហែល២នាទី។ ក្រោយមកក្រុមគ្រួសារ ង៉ែត យុន បានទៅសួរសុខទុក្ខជាបន្តបន្ទាប់ ពួកគេយល់ថា ង៉ែត យុន ក្រៀមក្រំ និងមានសុខភាពខ្សោយ។ អ្វីដែលធ្វើឲ្យក្រុមគ្រួសារនេះបារម្ភបំផុត គឺសុខភាពរបស់ ង៉ែត យុន ពីព្រោះ ង៉ែត យុន មានជម្ងឺ ហើយតម្រូវអោយទទួលការព្យាបាលជាប្រចាំ។

មុននឹងពេល ដែលគេត្រូវបានគេចាប់ខ្លួន ង៉ែត យុន គឺជាអ្នកថែរក្សាស្វាមី និងចៅទាំងបី។ ចៅៗទាំងបីមានការនឹករលឹកលោកយាយជាខ្លាំង ហើយចេះតែសួរថា ពេលណាលោកយាយត្រលប់មកផ្ទះវិញ ហើយហេតុអីបានជាគាត់ជាប់ពន្ធនាគារ។

## លី ចាន់ណារី



**អាសយដ្ឋាន:** ផ្ទះលេខ៧ ផ្លូវលេខ២៧១ ភូមិ១ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក
**អាយុ:** ៥០ ឆ្នាំ
**ស្ថានភាពគ្រួសារ:** រៀបការ មានកូនប្រុស៣នាក់ (ម្នាក់អាយុ៧ឆ្នាំ ១២ឆ្នាំ និង១៥ឆ្នាំ)
**ឈ្មោះហៅក្រៅ:**៣៧
**មុខរបរ:** មេផ្ទះ
**ប័ណ្ណកម្មសិទ្ធិ:**ត្រូវគេកាត់ចេញដោយបំពាន
**ថ្ងៃចាប់ខ្លួន:** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ **ដោះលែងអោយនៅក្រៅឃុំបណ្តោះអាសន្ន:** ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ (ជនជាប់ចោទត្រូវបង្ហាញខ្លួននៅមុខរាល់ពេលកោះហៅដោយចៅក្រមស៊ើបអង្កេត មិនត្រូវផ្លាស់ប្តូរទីលំនៅ និងត្រូវមកបង្ហាញខ្លួននៅមុខប៉ុស្តិ៍នគរបាលឲ្យបានទៀងទាត់)

***សុខ ស៊ាង ជាបងស្រី លី ចាន់ណារី បញ្ជាក់ថា "គ្រប់គ្នាចូលរួមតវ៉ា តែខ្ញុំមិនយល់សោះថាហេតុអ្វី បានជាពួកគេចាប់ប្អូនស្រីខ្ញុំ។ ឬមួយពួកគេដឹងថាពួកយើងជាសហគមន៍ភូមិបឹងកក់?"***

លី ចាន់ណារី ត្រូវចាប់ខ្លួនកាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ នៅខាងមុខសាលាដំបូងរាជធានីភ្នំពេញ នៅពេលនាងរៀបចំឯកសារចូលទៅធ្វើសក្ខីកម្មឲ្យអ្នកតំណាងបឹងកក់ទាំង១៣នាក់។ លី ចាន់ណារី ក៏មានវត្តមានក្នុងពេលតវ៉ាថ្ងៃទី២២ ខែឧសភា ដែរ ប៉ុន្តែនាងគ្រាន់តែទៅមើលដោយមិនបានចូលរួមតវ៉ាឲ្យសកម្មនោះទេ។

លី ចាន់ណារី និងក្រុមគ្រួសារឈប់រស់នៅក្នុងតំបន់បឹងកក់នេះតទៅទៀតហើយ ចាប់តាំងពីផ្ទះ និងទ្រព្យសម្បត្តិភាគច្រើនរបស់នាងត្រូវបានក្រុមហ៊ុនកំទិចកាលពីឆ្នាំ២០១០។ ហើយមិនបានទទួលសំណងអ្វីទាល់តែសោះ។ ក្រុមគ្រួសារនាង អាចប្រមូលបានតែទ្រព្យបន្តិចបន្តួច ដែលលើកបានដោយដៃ មុនពេលផ្ទះទាំងមូលត្រូវលិចក្នុងខ្សាច់។ ក្រុមគ្រួសារនាងមានដីខ្លះនៅបឹងកក់ក៏បានត្រូវបាត់បង់ដែរ។

ក្រុមគ្រួសារ លី ចាន់ណារី មានគ្នាសរុប៧នាក់ គឺចាន់ ណារី ស្វាមី កូនប្រុស៣នាក់ ប្អូនស្រី និងម្តាយចាស់។ ក្រុមគ្រួសារទាំងអស់មិនសូវជាសកម្មក្នុងការតវ៉ាជាមួយអ្នកបឹងកក់ទេ ហេតុដូច្នេះក្រុមគ្រួសារមិនយល់ថា ហេតុអ្វីបានជា លី ចាន់ណារីត្រូវបានគេចាប់ខ្លួន? ជាពិសេសកូនទាំង ៣ នាក់ចេះតែសួរថា "ពេលណាទើបម្តាយត្រលប់មកផ្ទះវិញ"។

## សៅ សារឿន



**អាសយដ្ឋាន:**ភូមិ១
**អាយុ:** ៧២ ឆ្នាំ
**ស្ថានភាពគ្រួសារ:** រៀបការ មានកូន៣នាក់ និងចៅ៧នាក់ (កូនៗធ្វើការទាំងអស់)
**ឈ្មោះហៅក្រៅ:**គ្មាន
**មុខរបរ:**ចូលនិវត្តន៍
**ប័ណ្ណកម្មសិទ្ធិ:** ត្រូវគេកាត់ចេញដោយបំពាន
**ថ្ងៃចាប់ខ្លួន:** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
**ដោះលែងអោយនៅក្រៅឃុំបណ្ដោះអាសន្ន:** ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ (ចុងចោទត្រូវបង្ហាញខ្លួននៅមុខរាល់ពេលកោះហៅ ដោយចៅក្រមស៊ើបអង្កេតមិនត្រូវផ្លាស់ប្តូរទីលំនៅ និងត្រូវមកបង្ហាញខ្លួននៅមុខប៉ុស្តិ៍នគរបាលឲ្យបានទៀងទាត់)

***ភរិយារបស់លោក សៅ សារឿន បានមានប្រសាសន៍ថា "ស្វាមីរបស់ខ្ញុំត្រូវបានជាប់ក្នុងពន្ធនាគារ ប៉ុន្តែលោកអត់បានប្រព្រឹត្តអ្វីខុសទាល់តែសោះ"***

សៅ សារឿន អាយុ៧២ឆ្នាំ ត្រូវបានគេចាប់ខ្លួនកាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ នៅពេលដែលលោកកំពុងពិសារកាហ្វេនៅក្នុងតៀមមួយក្បែរសាលាដំបូងរាជធានីភ្នំពេញ។ ខណ:ពេល ដែលលោកបានរៀបចំឯកសារត្រៀមខ្លួនចូលទៅធ្វើសក្ខីកម្មឲ្យអ្នកតំណាងបឹងកក់ទាំង ១៣ នាក់។

លោកសៅ សារឿន មានដីមួយកន្លែងក្នុងតំបន់បឹងកក់។ នគរបាលបានតាមឃ្លាំមើលសកម្មភាពលោកយ៉ាងជាប់លាប់។

នៅថ្ងៃចាប់ខ្លួន ភរិយាលោកសៅ សារឿន បានទទួលទូរស័ព្ទពីអ្នកជិតខាងម្នាក់បានផ្តល់ព័ត៌មានថា ស្វាមីរបស់គាត់គេត្រូវចាប់ខ្លួន។ ទុកជាមានការស្នើសុំជាច្រើនដងក៏ដោយ ក៏ភរិយារបស់លោកមិនបានអនុញ្ញាតឲ្យចូលសួរសុខទុក្ខស្វាមីទេ រហូត៣ថ្ងៃក្រោយមកទើបបានជួប។ ភរិយាលោកបានសង្កេតឃើញថា លោកមានការភ័យខ្លាច ហើយនាងពិតជាបារម្ភអំពីសុខភាពរបស់ស្វាមីពីព្រោះតែស្វាមីនាងមានបញ្ហាសុខភាព ដែលតម្រូវឲ្យទទួលបានការព្យាបាលជាប្រចាំ។